**សលាកប័ត្រព័ត៌មាន** ៖ ការសួរសុខទុក្ខនៅពន្ធនាគារ

**ពេលវេលា** ៖ ខែមីនា ឆ្នាំ២០១៥

**ទិដ្ឋភាពរួម** ៖ ការរឹតបន្តឹងបែបការិយាធិបតេយ្យនាពេលថ្មីៗនេះបានរាំងស្ទះ ម.ស.ម.ក ក្នុងការរៀបចំទស្សនកិច្ចនៅពន្ធនាគារ ដែលធ្វើឲ្យបះពាល់ដល់តួនាទីជាវិជ្ជមានរបស់អង្គការសង្គមស៊ីវិល ក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនៅថ្នាក់ជាតិ ដើម្បីឃ្លាំមើលទីកន្លែងឃុំឃាំង បង្កើនកិច្ចការពារដល់ជនជាប់ឃុំ និងពង្រឹងតម្លាភាព និងគណនេយ្យភាព។

## សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះ ផ្តល់នូវទិដ្ឋភាពទូទៅស្តីពីឧបសគ្គដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានប្រឈមនាពេលថ្មីៗនេះ ក្នុងការប៉ុនប៉ងរៀបចំទស្សនកិច្ចពន្ធនាគារ ដើម្បីផ្តល់ការគាំទ្រដល់ជនដែលសេរីភាពរបស់ពួកគេត្រូវបានដកហូតដោយសារការអនុវត្តសេរីភាពមូលដ្ឋាន។ បើទោះបីជា អង្គការសង្គមស៊ីវិលមានតួនាទីដ៏សំខាន់ក្នុងការអនុវត្តការងារត្រួតពិនិត្យស្ថានភាពសិទ្ធិមនុស្សនៅទីកន្លែងឃុំឃាំងដោយឯករាជ្យយ៉ាងណាក៏ដោយ ក៏រដ្ឋាភិបាលបានរឹតត្បិតក្នុងការចូលទៅពន្ធនាគារជាច្រើនលើកច្រើនសារនាពេលថ្មីៗនេះ។

ម.ស.ម.ក គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។

## សាវតានៃករណី

នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ ម.ស.ម.ក បានស្នើសុំការអនុញ្ញាតពីអគ្គនាយកដ្ឋានពន្ធនាគារ ដែលជានាយកដ្ឋានមួយនៃក្រសួងមហាផ្ទៃ ដើម្បីឲ្យក្រុមការងាររបស់ ម.ស.ម.ក ចូលសួរសុខទុក្ខលោក វន់ ពៅ និងអ្នកជាប់ឃុំប្រាំពីរនាក់ផ្សេងទៀតដែលត្រូវបានចាប់ខ្លួន ខណៈពេលធ្វើបាតុកម្មដោយសន្តិវិធី ទាមទារតំឡើងប្រាក់ខែអប្បបរិមា ១៦០ ដុល្លារ នៅមុខរោងចក្រយ៉ាក់ជីងកាលពីថ្ងៃទី២ ខែមករា ឆ្នាំ២០១៤។ សំណើនោះត្រូវបានច្រានចោលដោយសំអាងថា រឿងក្តីកំពុងស្ថិតក្នុងដំណាក់កាលស៊ើបអង្កេត ដូច្នេះមានតែក្រុមគ្រួសារ និងមេធាវីប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឲ្យជួបសួរសុខទុក្ខអ្នកជាប់ឃុំទាំងនោះ។ ម.ស.ម.ក បានបង្ហាញថា មានតែចៅក្រមស៊ើបអង្កេត

ប៉ុណ្ណោះដែលអាចហាមប្រាមការជួបសួរសុខទុក្ខ ដើម្បីធានាថាការស៊ើបអង្កេតនោះប្រព្រឹត្តទៅបានល្អ ហេតុដូច្នេះ ការបដិសេធនោះពុំមានមូលដ្ឋានច្បាប់ឡើយ។[1]

នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៤ ម.ស.ម.ក បានស្នើសុំការអនុញ្ញាតចូលសួរសុខទុក្ខស្ត្រីមកពីតំបន់បឹងកក់រួមមាន ង៉ែត ឃុន, ទេព វន្នី, សុង ស្រីលាភ, គង់ ចន្ថា, ផាន់ ឈុនរ៉េត, បូ ឆវី, និង នង ស្រេង ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤ ដោយចោទប្រកាន់ពីបទរារាំងចរាចរណ៍សាធារណៈ ហើយត្រូវបានកាត់ និងផ្តន្ទាទោសក្នុងរយៈពេល ៣៦ ម៉ោង ដោយទទួលទោសជាប់ពន្ធនាគារអតិបរមារយៈពេល ១ ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០០ ដុល្លារសហរដ្ឋអាមេរិក។[2] ស្ត្រីទាំង ៧ នាក់ បានធ្វើបាតុកម្មប្រឆាំងតវ៉ា ដើម្បីឲ្យអាជ្ញាធរចាត់វិធានការចំពោះបញ្ហាទឹកលិចនៅក្នុងសហគមន៍របស់គាត់។ តំបន់នេះរងគ្រោះដោយសារទឹកលិចតាំងពីឆ្នាំ ២០០៨ នៅពេលមានការចាក់ខ្សាច់បំពេញបឹង ដោយក្រុមហ៊ុន ស៊ូកាគូ អ៊ីន។ នៅក្នុងសំណើសួរសុខទុក្ខបានបញ្ចូលឈ្មោះកញ្ញា លី ស្រ៊ាវមិញ និងឪពុកគឺលោក លី ស្រ៊ាខេង ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ក្នុងបរិបទជម្លោះដីធ្លីជាមួយក្រុមហ៊ុន យុន សៀ អ៊ឹមផត អិចផត បន្ទាប់ពីពួកគេមិនព្រមចាកចេញពីទីតាំងដីមានជម្លោះនៅតំបន់បឹងកក់១ នៅទីក្រុងភ្នំពេញ។ ក្រុមគ្រួសារនេះរងការគំរាមកំហែងសម្លាប់ការវាយប្រហារដោយហិង្សា និងការសម្លុតបំភ័យ។ លោក ខេង ត្រូវបានអនុញ្ញាតឲ្យនៅក្រៅឃុំនៅថ្ងៃទី៥ ខែធ្នូ ប៉ុន្តែតុលាការបានបដិសេធសំណើសុំនៅក្រៅឃុំរបស់កញ្ញា ស្រ៊ាវមិញ នៅថ្ងៃទី៥ ខែមករា ដោយសំអាងលើហេតុផលការពារការប្រព្រឹត្តបទល្មើសបន្ថែមទៀត ការបំផ្លាញភស្តុតាង ឬគំរាមកំហែងសាក្សីដោយពុំមានការពន្យល់ពីមូលហេតុដែលហានិភ័យបែបនេះអាចកើតឡើងក្នុងរឿងនេះទេ។[3] លោក លី ស្រ៊ាខេង ត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន។ បច្ចុប្បន្នអ្នកទាំងប្រាំបីផ្សេងទៀតគឺកំពុងជាប់ឃុំនៅមណ្ឌលអប់រំកែប្រែពីរ នៅជាយក្រុងភ្នំពេញ។

ម.ស.ម.ក បានទទួលលិខិតឆ្លើយតបមួយនៅថ្ងៃទី១៦ ខែធ្នូ ដែលបានចុះហត្ថលេខានៅថ្ងៃទី៤ ខែធ្នូ ដោយសរសេរថា ការសួរសុក្ខទុក្ខមិនត្រូវបានអនុញ្ញាតឡើយ ដោយសារក្នុងសំណើបានប្រើពាក្យថា "សកម្មជន" នៅក្នុងមន្ទីរឃុំឃាំង ដែលការសួរសុខទុក្ខគួរធ្វើឡើងចំពោះ "អ្នកជាប់ឃុំទូទៅដែលពុំមានសាច់ញាតិ"។ គណៈប្រតិភូមួយក្រុមរួមមានបុគ្គលិក ម.ស.ម.ក និងអង្គការពិភពលោកប្រឆាំងនឹងអំពើទារុណកម្ម ("OMCT") តាមពិតត្រូវបានអនុញ្ញាតឲ្យសួរសុខទុក្ខ ទេព វន្នី និងសុង ស្រីលាភ នៅក្នុងពន្ធនាគារកាលពីថ្ងៃទី២ ខែធ្នូ តែយ៉ាងនេះក្តី បុគ្គលិករបស់ ម.ស.ម.ក បានប្រាប់ថា

---

1 លិខិតចំហរបស់ ម.ស.ម.ក ការបដិសេធឲ្យសួរសុខទុក្ខលោកវន់ ពៅ និងជនជាប់ឃុំប្រាំពីរនាក់ផ្សេងទៀតដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ https://docs.google.com/viewerng/viewer?url=http://www.cchrcambodia.org/media/files/press_release/467_202ccltm%28_en.pdf

2 ម.ស.ម.ក, ' សមាជិកសហគមន៍បឹងកក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន និងផ្តន្ទាទោសក្នុងរយៈពេល ៣៦ ម៉ោង' (ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០១៤), http://bit.ly/15M7uOu

3 សេចក្តីថ្លែងការណ៍រួម របស់អង្គការសង្គមស៊ីវិល 'ការចាប់ខ្លួនតាមអំពើចិត្តនៅក្នុងតំបន់បឹងកក់ ១' (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤) <http://cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=524&id=5>

គាត់ចូលទៅសួរសុខទុក្ខនេះគ្រាន់តែជាអ្នកជួយបកប្រែដល់បុគ្គលិកអង្គការពិភពលោកប្រឆាំងនឹងអំពើទារុណកម្មប៉ុណ្ណោះ មិនមែនក្នុងនាមជាបុគ្គលិករបស់ ម.ស.ម.ក នោះទេ។ លើសពីនេះទៀត ក្រុមការងារ ម.ស.ម.ក ត្រូវបានអនុញ្ញាតឲ្យជួប ទេព វន្នី, សុង ស្រីលាភ, គង់ ចន្ថា និង ង៉ែត យុន នៅថ្ងៃទី២៣ ខែធ្នូ ប៉ុន្តែ ជួបក្នុងនាមជាមិត្តភ័ក្តរបស់អ្នកជាប់ឃុំ មិនមែនក្នុងនាមជាបុគ្គលិករបស់ម.ស.ម.ក នោះទេ។

នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ ម.ស.ម.ក បានដាក់លិខិតមួយច្បាប់ទៀតជូនឯកឧត្តម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីស្នើសុំសួរសុខទុក្ខជនជាប់ឃុំទាំងប្រាំបីនាក់ចំនួនពីរដងក្នុងមួយខែ។ ប្រាំមួយសប្តាហ៍ក្រោយមក គឺនៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ទើបម.ស.ម.ក បានទទួលការឆ្លើយតបពីក្រសួងមហាផ្ទៃ ដោយអនុញ្ញាតឲ្យជួបជាផ្លូវការតែម្តងគត់នៅក្នុងខែកុម្ភៈ។ លិខិតនោះបានចុះហត្ថលេខានៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ តែត្រូវបានបញ្ជូនមកក្នុងរយៈពេលប្រាំមួយថ្ងៃបន្ទាប់ ដែលធ្វើឲ្យការអនុញ្ញាតិនេះមិនអាចយកជាការបាន។ ម.ស.ម.ក នឹងដាក់សំណើសួរសុខទុក្ខរបស់ខ្លួនជាថ្មីរហូតទាល់តែទទួលបានការអនុញ្ញាត។

នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥ គណៈប្រតិភូដែលមានទាំងបុគ្គលិកជាតិ និងអន្តរជាតិរបស់ ម.ស.ម.ក មានបំណងចូលទៅជួបជនជាប់ឃុំមួយចំនួននៅមណ្ឌលអប់រំកែប្រែទីពីរ ព្រៃស រួមមាន ទេព វន្នី, លី ស៊ាវមិញ និង សុង ស្រីលាភ។ បើទោះបីជាលើកនេះពួកគេលាក់បាំងពីសមាសភាពជាបុគ្គលិក ម.ស.ម.ក ក៏ដោយ មន្ត្រីពន្ធនាគារបានប្រាប់ថាក្រុមគណៈប្រតិភូថា ខ្លួនបានទទួលបទបញ្ជាផ្ទាល់មាត់ពីថ្នាក់លើមិនអនុញ្ញាតឲ្យជនបរទេសចូលជួបដោយមិនមានលិខិតអនុញ្ញាតជាផ្លូវការពីអគ្គនាយកដ្ឋានពន្ធនាគារ ឬស្ថានទូតឡើយ។ បុគ្គលិកជាតិម្នាក់ក្នុងចំណោមគណៈប្រតិភូត្រូវបានអនុញ្ញាតឲ្យជួបជនជាប់ឃុំម្នាក់ក្នុងនាមជាមិត្តភ័ក្ត។ ជាថ្មីម្តងទៀត នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ បុគ្គលិកដដែលស្នើសុំជួប ទេព វន្នី ក្នុងនាមជាមិត្តភ័ក្ត ហើយគាត់ក៏អាចជួបជាមួយជនជាប់ឃុំ ៦នាក់ផ្សេងទៀតក្នុងពេលជាមួយគ្នាដែលមេធាវីរបស់ពួកគេកំពុងជួបសួរសុខទុក្ខផងដែរ។

អង្គការសិទ្ធិមនុស្សផ្សេងទៀតរួមមាន លីកាដូ និង អាដហុក ក៏ប្រឈមនឹងការលំបាក នៅពេលរៀបចំទស្សនកិច្ចពន្ធនាគារនាពេលថ្មីៗនេះផងដែរ។[4]

## ការត្រួតពិនិត្យដោយឯករាជ្យទៅលើស្ថានភាពសិទ្ធិមនុស្សនៅកន្លែងឃុំឃាំង

មាត្រា៥៥ នៃច្បាប់ស្តីពីពន្ធនាគារអនុញ្ញាតឲ្យសមាជិកគ្រួសារសួរសុខទុក្ខអ្នកជាប់ឃុំឃាំង ប៉ុន្តែច្បាប់នៅប្រទេសកម្ពុជាផ្តល់នូវការណែនាំតិចតួចដល់សមាជិកអង្គការសង្គមស៊ីវិលក្នុងការជួបជាមួយអ្នកជាប់ឃុំ ហើយហាក់ដូចជាពុំមានភាពស៊ីសង្វាក់គ្នានឹងការអនុវត្ត។ ការសួរសុខទុក្ខជាទៀង

[4] http://www.licadho-cambodia.org/pressrelease.php?perm=378&khmer
http://www.rfa.org/khmer/news/human-rights/Adhoc-disappointed-with-prison-dept-03052015000809.html?searchterm:utf8:ustring=%E1%9E%9F%E1%9E%98%E1%9E%B6%E1%9E%82%E1%9E%98%E2%80%8B%E1%9E%A2%E1%9E%B6%E1%9E%8A%E1%9E%A0%E1%9E%BB%E1%9E%80

ទាត់នៅទីកន្លែងឃុំឃាំងត្រូវបានទទួលស្គាល់ថា អាចជួយពង្រឹងការការពារដល់បុគ្គលដែលត្រូវបានដកហូតសេរីភាព ប្រឆាំងនឹងការរំលោភបំពានសិទ្ធិមនុស្ស។ យោងទៅលើមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា “ត្រូវទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញ អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ”។ ឧទាហរណ៍ ពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (“ពិធីសារបន្ថែម”)[5] ដែលកម្ពុជាផ្តល់សច្ចាប័ននៅឆ្នាំ២០០៧ បានចែងនៅក្នុងបុព្វកថា ថា “ការការពារជនទាំងឡាយដែលត្រូវបានដកហូតសិទ្ធិសេរីភាពឲ្យរួចផុតពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប អាចត្រូវពង្រឹងដោយវិធានការក្រៅផ្លូវតុលាការ ដែលមានចរិតជាការបង្ការ ដោយផ្អែកលើការចូលពិនិត្យជាទៀងទាត់នៅកន្លែងឃុំឃាំងនានា។”

ពិធីសារបន្ថែមនេះទទួលស្គាល់ថា យន្តការត្រួតពិនិត្យនៅថ្នាក់ជាតិ និងអន្តរជាតិដែលឯករាជ្យពីសំណាក់អាជ្ញាធរពន្ធនាគារ គឺជាគន្លឹះក្នុងការធានានូវសុវត្ថិភាពគ្រប់គ្រាន់ បង្កើតនូវអនុគណៈកម្មការអន្តរជាតិការពារអំពើទារុណកម្ម និងផ្តល់នូវការបង្កើតយន្តការការពារថ្នាក់ជាតិ។

ម.ស.ម.ក ជឿជាក់ថា អង្គការសង្គមស៊ីវិលអាចដើរតួនាទីសំខាន់ក្នុងការខិតខំប្រឹងប្រែងនៅថ្នាក់ជាតិ ដើម្បីត្រួតពិនិត្យនៅកន្លែងឃុំឃាំង ធានាការការពារដល់ជនជាប់ឃុំ និងពង្រឹងតម្លាភាព និងគណនេយ្យភាព។ ករណីនេះពិតជាមានសារសំខាន់នៅក្នុងប្រទេសកម្ពុជា ដោយសារការគ្រប់គ្រងរបស់រដ្ឋាភិបាល ភាគច្រើនពន្ធនាគារមានសភាពចាស់ៗ ហើយ “មិនបានអនុវត្តទៅតាមស្តង់ដារអន្តរជាតិ” [6] កម្ពុជាខ្វះខាតនូវប្រព័ន្ធយុត្តិធម៌សម្រាប់អនីតិជន[7] និងរងការចោទប្រកាន់ធ្ងន់ធ្ងរទាក់ទងនឹងការរំលោភបំពាននៅក្នុងមន្ទីរឃុំឃាំង ចំពោះអ្នកដែលគ្មានផ្ទះសំបែង និងជន “អនាថា” [8] ហើយរដ្ឋាភិ

---

[5] ពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលអនុម័តនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ ក្នុងកិច្ចប្រជុំលើកទី៥៧ របស់មហាសន្និបាតអង្គការសហប្រជាជាតិតាមយៈដំណោះស្រាយលេខ៥៧ ១៩៩ ចូលជាធរមាននៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ អាចមើលបានតាមរយៈ http://www.ohchr.org/EN/ProfessionalInterest/Pages/OPCAT.aspx

[6] ក្រុមប្រឹក្សាសិទ្ធិមនុស្ស បញ្ជីបញ្ហាពាក់ព័ន្ធនឹងរបាយការណ៍ស្តីពីកម្ពុជាដែលត្រូវត្រួតពិនិត្យលើកទី២ ( CCPR/C/KHM/Q/2/Add.1) ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ទំព័រ៨

[7] សូមមើលទំព័រ១២

[8] អង្គការឃ្លាំមើលសិទ្ធិមនុស្ស កម្ពុជា ៖ មរណភាពបង្ហាញពីការបំពាបំពាននៅមន្ទីរឃុំឃាំង ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៤ http://www.hrw.org/news/2014/12/06/cambodia-death-highlights-detention-center-abuses

បាលនៅពុំទាន់បង្កើតវិទ្យាស្ថានសិទ្ធិមនុស្សថ្នាក់ជាតិដូចដែលបានកំណត់នៅក្នុងគោលការណ៍ទីក្រុងប៉ារីសដែលមានអំណាចក្នុងការត្រួតពិនិត្យយ៉ាងទៀងទាត់នៅឡើយ។

អង្គការសង្គមស៊ីវិលមានជំនាញច្បាស់លាស់ចំពោះស្ថានភាពសិទ្ធិមនុស្សនៅថ្នាក់មូលដ្ឋាន ហើយដូចដែលបានចង្អុលបង្ហាញដោយសមាគមការពារការធ្វើទារុណកម្ម ដែលអាចសង្កេតពិនិត្យផ្ទាល់ ជាក់លាក់ពីស្ថានភាពជនដែលត្រូវបានដកហូតសេរីភាព។[9] ការរឹតត្បិតអង្គការសង្គមស៊ីវិលក្នុងការសួរសុខទុក្ខដល់បុគ្គលដែលត្រូវបានដកហូតសេរីភាព អាចនឹងរារាំងដល់ការយកចិត្តទុកដាក់ និងការគាំទ្រផ្នែកស្មារតី ។ ជាងនេះទៅទៀត អវត្តមាននៃយន្តការត្រួតពិនិត្យថ្នាក់ជាតិដែលអនុញ្ញាតឲ្យអង្គការសង្គមស៊ីវិលត្រួតពិនិត្យយ៉ាងទៀងទាត់នៅទីកន្លែងឃុំខ្លួន អាចជាពេលវែងឆ្ងាយដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការការពារបុគ្គលដែលត្រូវបានដកហូតសេរីភាពប្រឆាំងនឹងការរំលោភបំពានសិទ្ធិមនុស្ស។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកញ្ញា ឆាយ ឈុនលី មន្ត្រីសម្របសម្រួលគម្រោងការពារសេរីភាពមូលដ្ឋានរបស់ ម.ស.ម.ក តាមរយៈទូរសព្ទ ៖ (+៨៥៥)១៧ ៥២៨ ០២១ ឬ តាមរយៈអ៊ីមែល chhunly.chhay@cchrcambodia.org ឬ លោកស្រី ម៉ាតា រីហ្គី ទីប្រឹក្សា តាមរយៈទូរសព្ទ ៖ (+៨៥៥)១៣ ៥៩០ ៦៧១ ឬ អ៊ីមែល ៖ marta.riggio@cchrcambodia.org ។**

[9] សមាគមការពារអំពើទារុណកម្ម ‘សង្គមស៊ីវិល’ http://www.apt.ch/en/civil-society/